


សារលិខិតសន្និសីទមកពីព្យាការី



ដោយប្រធាន រ័សុល អិម
ណិលសុន

# ព្រះយេស៊ូវគ្រីស្ទ នឹងយាងមកម្ដងទៀត

ព្រះអង្គសង្គ្រោះបានធ្វើការសន្យានេះចំពោះបងប្អូនថា ៖ « យើងនឹងនៅខាងស្ដាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់យើងនឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ហើយពួកទេវតារបស់យើងនៅព័ទ្ធជុំវិញអ្នក ដើម្បីទ្រអ្នកឡើង » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៤:៨៨ ) ។

ព្រះយេស៊ូវគ្រីស្ទបានលើកដាក់លើអង្គទ្រង់នូវ *អំពើបាប* របស់បងប្អូន *ការឈឺចាប់* របស់បងប្អូន និង *ការឈឺចិត្ត* របស់បងប្អូន ។ ទ្រង់នឹងអត់ទោសដល់បងប្អូន នៅពេលដែលបងប្អូនប្រែចិត្ត ។ ទ្រង់នឹងប្រទានពរដល់បងប្អូននូវអ្វីដែលបងប្អូនត្រូវការ ។

ថ្ងៃនេះ ខ្ញុំសូមអំពាវនាវឲ្យបងប្អូនជួយរៀបចំពិភពលោកសម្រាប់ **ការយាងមកជាលើកទីពីរ** របស់ព្រះអម្ចាស់ ។ ខ្ញុំសូមអំពាវនាវឲ្យបងប្អូននិយាយអំពីព្រះគ្រីស្ទ ថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ មានសេចក្ដីជំនឿលើព្រះគ្រីស្ទ និងអររីករាយក្នុងព្រះគ្រីស្ទ ! នេះគឺជាអាថ៌កំបាំងនៃជីវិតដ៏មានអំណររីករាយ ។

អ្វីដែលល្អបំផុតនឹងមកដល់ក្នុងពេលខាងមុខ ពេលយើងបង្វែរដួងចិត្ត និងជីវិតទៅរកព្រះយេស៊ូវគ្រីស្ទ ។ ●

*កែសម្រួលពី « ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទនឹងយាងមកម្ដងទៀត » លីអាហូណា ខែវិច្ឆិកា ឆ្នាំ២០២៤ ទំព័រ ១២១–១២២ ។*

**ការយាងមកជាលើកទីពីរ ៖**

នៅពេលដែលព្រះយេស៊ូវគ្រីស្ទនឹងយាងមកផែនដីម្ដងទៀត

## រៀបចំខ្លួនពេលទ្រង់យាងមកម្ដងទៀត

ប្រធាន ណិលសុន បានអញ្ជើញយើងឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមគូររូបភាពអំពីអ្វីដែលប្អូនៗនឹងធ្វើដើម្បីរៀបចំខ្លួន ។ សូមមើលខាងក្រោមសម្រាប់គំនិតមួយចំនួនពីសុន្ទរកថារបស់ប្រធាន ណិលសុន !



ធ្វើ ហើយរក្សាសេចក្ដីសញ្ញា

ជួយនាំមនុស្សដទៃទៅរកព្រះយេស៊ូវគ្រីស្ទ

រៀបចំខ្លួនចូលព្រះវិហារបរិសុទ្ធ

រៀនអំពីព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់